ធនាគារជាតិនៃកម្ពុជា
NATIONAL BANK OF CAMBODIA

NATIONAL BANK OF RWANDA
BANKI NKURU Y' U RWANDA

ថ្ងៃអាទិត្យ ៦កើត ខែកត្តិក ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០២៦

សេចក្តីប្រកាសព័ត៌មានរួម
ស្តីពី
ការធ្វើតេស្តសាកល្បង (Proof of Concept) លើសេវាផ្ទេរប្រាក់ឆ្លងដែន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋរវ៉ាន់ដា

នាថ្ងៃអាទិត្យ ៦កើត ខែកត្តិក ឆ្នាំមមី អដ្ឋស័ក ពុទ្ធសករាជ ២៥៧០ ត្រូវនឹងថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០២៦ ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលរវ៉ាន់ដា បានប្រកាសចាប់ផ្តើមធ្វើតេស្តសាកល្បង (Proof of Concept) លើសេវាផ្ទេរប្រាក់ឆ្លងដែនរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋរវ៉ាន់ដា ដែលអនុញ្ញាតឱ្យប្រជាជនកម្ពុជាអាចផ្ទេរប្រាក់ឆ្លងដែនទៅប្រទេសរវ៉ាន់ដាបានយ៉ាងឆាប់រហ័ស និងប្រកបដោយសុវត្ថិភាព។ ការធ្វើតេស្តសាកល្បងនេះត្រូវបានរៀបចំឡើងនៅក្នុងវេទិកាហិរញ្ញវត្ថុអន្តរជាតិ Black Swan Summit Cambodia ដែលប្រព្រឹត្តទៅនៅថ្ងៃទី ១៥-១៦ ខែវិច្ឆិកា ឆ្នាំ ២០២៦ នៅរាជធានីភ្នំពេញ។

សេវាផ្ទេរប្រាក់ឆ្លងដែននេះត្រូវបានអភិវឌ្ឍឡើងក្រោមកិច្ចសហការនៃការតភ្ជាប់ប្រព័ន្ធទូទាត់បាគង (Bakong) របស់ប្រទេសកម្ពុជា និងប្រព័ន្ធទូទាត់ជាតិ eKash ដែលដំណើរការដោយ RSwitch របស់ប្រទេសរវ៉ាន់ដា ចំណែកធនាគារ អេស៊ីលីដា ភីអិលស៊ី ដើរតួជាធនាគារទំនាក់ទំនងក្នុងប្រទេសកម្ពុជា និងធនាគារ I&M Bank ជាធនាគារទូទាត់ក្នុងប្រទេសរវ៉ាន់ដា។ តាមរយៈការតភ្ជាប់នេះ អតិថិជនរបស់ធនាគារទំនាក់ទំនង និងគ្រឹះស្ថានដែលជាសមាជិកបាគងនៅកម្ពុជា អាចផ្ទេរប្រាក់ឆ្លងដែនដោយផ្ទាល់ទៅកាន់គណនីធនាគារ និងកាបូបឌីជីថលរបស់អ្នកទទួលប្រាក់នៅប្រទេសរវ៉ាន់ដា បានយ៉ាងឆាប់រហ័ស ងាយស្រួល មានសុវត្ថិភាព និងតម្លៃសមរម្យ ព្រមទាំងកាត់បន្ថយភាពស្មុគស្មាញក្នុងការផ្ទេរប្រាក់ឆ្លងប្រទេស។

គម្រោងនេះ នឹងផ្តល់ជម្រើសបន្ថែមក្នុងការផ្តល់សេវាហិរញ្ញវត្ថុសម្រាប់បុគ្គល និងធុរកិច្ច ដែលមានតម្រូវការផ្ទេរប្រាក់រវាងប្រទេសទាំងពីរ ព្រមទាំងសម្រួលដល់ការទូទាត់ពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ និងជំរុញបរិយាបន្នហិរញ្ញវត្ថុ តាមរយៈការលើកកម្ពស់លទ្ធភាពទទួលបានសេវាផ្ទេរប្រាក់ផ្លូវការ និងសេវាហិរញ្ញវត្ថុឌីជីថល ជាពិសេសរួមចំណែកជំរុញសកម្មភាពសេដ្ឋកិច្ចនៃប្រទេសទាំងពីរឱ្យកាន់តែប្រសើរឡើង។

ទំនាក់ទំនង៖

ធនាគារជាតិនៃកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ៩៩០ ១៨៩ អ៊ីម៉ែល៖ nbccommunications@nbc.gov.kh គេហទំព័រ៖ www.nbc.gov.kh ហ្វេសប៊ុក៖ ធនាគារជាតិ នៃកម្ពុជា - National Bank of Cambodia បណ្តាញ X៖ nbccambodia	**ធនាគារកណ្តាលរវ៉ាន់ដា** ទូរសព្ទ៖ (250) 788 199 000 អ៊ីម៉ែល៖ communications@bnr.rw គេហទំព័រ៖ www.bnr.rw ហ្វេសប៊ុក/Instagram/X៖ @CentralBankRw